柬埔寨文
កម្ពុជា

រចនាសម្ព័ន្ធស្នើសុំចុះបញ្ជីធ្វើតួបនីយកម្មជាចិនតៃវ៉ាន់របស់ជនបរទេស បន្ទាប់បានរៀបការជាមួយជនតៃវ៉ាន់

ខ្សែសង្វាក់ស្នើសុំ	ស្ថាបនៈទទួលពិនិត្យ និងដោះស្រាយ	ឯកសារដែលត្រូវប្រគល់អោយ
ការចុះបញ្ជីអាពាហ៍ពិពាហ៍	ការិយាល័យអត្រានុកូលដ្ឋាន	១. អ្នករៀបការនៅក្នុងស្រុក （១）សំបុត្រអាពាហ៍ពិពាហ៍（២）ឯកសារបញ្ជាក់ស្តីអត្តសញ្ញាណរបស់ប្តីប្រពន្ធបរទេសនិងលិខិតបញ្ជាក់សាភាពរៀបការដែលពិនិត្យបញ្ជាក់និងទទួលស្គាល់ពីស្ថានឯកអគ្គរដ្ឋទូតឬស្ថានកុងស៊ុលប្រចាំនៅប្រទេសក្រៅនិងឯកសារបកប្រែជាភាសាចិន (ឯកសារភាសាចិនត្រូវទទួលការបញ្ជាក់ពីសារការី) និងសេចក្តីថ្លែងការណ៍ប្រើប្រាស់នាមនិងឈ្មោះភាសាចិន)（៣）សៀវភៅគ្រួសារឬសៀវភៅស្ថិតិគ្រួសារ（៤） អត្តសញ្ញាណប័ណ្ណពលរដ្ឋនិងត្រា ។ ២. អ្នករៀបការនៅក្រៅស្រុកនៅបរទេស（១）ឯកសារបញ្ជាក់អាពាហ៍ពិពាហ៍ដែលពិនិត្យបញ្ជាក់និងទទួលស្គាល់ពីស្ថានឯកអគ្គរដ្ឋទូតប្រចាំនៅបរទេសនិងឯកសារបកប្រែជាភាសាចិន（២）សៀវភៅគ្រួសារ（៣） អត្តសញ្ញាណប័ណ្ណពលរដ្ឋនិងត្រា（៤） ឯកសារបញ្ជាក់ពីអត្តសញ្ញាណរបស់ប្តីឬប្រពន្ធបរទេស ។（៥） ប្តីប្រពន្ធបរទេសដែលមិនអាចត្រឡប់មកតៃវ៉ាន់ចុះបញ្ជី ត្រូវតែភ្ជាប់ជាមួយនូវសេចក្តីថ្លែងការណ៍ស្តីពីការប្រើប្រាស់ឈ្មោះចិនដែលពិនិត្យបញ្ជាក់ដោយស្ថានទូត ។ ※ ប្រជាពលរដ្ឋចង់រៀបការជាមួយជនប្រទេសកំណត់ជាពិសេសដែលនៅក្នុងសេចក្តីប្រកាសនៃក្រសួងមហាផ្ទៃ ត្រូវតែចុះបញ្ជីអាពាហ៍ពិពាហ៍នៅប្រទេសដើមរបស់ប្តីឬប្រពន្ធបរទេសសិន រួចរៀបចំលិខិតបញ្ជាក់អាពាហ៍ពិពាហ៍និងលិខិតបកប្រែជាភាសាចិនទៅស្ថានទូតប្រចាំបរទេសស្នើសុំការពិភាក្សាផ្ទាល់មុខ ក្រោយពីឆ្លងកាត់ការការពិភាក្សាផ្ទាល់មុខ រួចយកលិខិតបញ្ជាក់ពាក់ព័ន្ធរបស់អ្នករៀបការនៅបរទេសទាំងអស់ខាងលើនេះ ទៅបំពេញបែបបទចុះបញ្ជីអាពាហ៍ពិពាហ៍ ។
ការស្នើសុំទិដ្ឋាការស្នាក់នៅ	បើអ្នកស្នើសុំនៅក្រៅប្រទេស គួរទៅទំនាក់ទំនងផ្ទាល់ជាមួយឯកអគ្គរដ្ឋទូតប្រចាំនៅបរទេស ដើម្បីស្នើសុំទិដ្ឋាការស្នាក់នៅរបស់អ្នកស្នើសុំបើគេបានកាន់ទិដ្ឋាការចុះចត្តផ្អែកតាមមូលហេតុសួរសុខទុក្ខពីញាតិសន្ដានគួរទៅសុំទិដ្ឋាការស្នាក់នៅវិញនៅស្ថានកុងស៊ុលក្រសួងការបរទេស(រួមទាំងទីចាត់ការភាគខាងកណ្តាល យូនចាណាន ភាគខាងត្បូង ភាគខាងកើតនៃក្រសួងការបរទេស) ។※បើអ្នកស្នើសុំចង់ចូលដែនចុះចតហួសរយៈពេល៦០ថ្ងៃ ដោយកាន់ទិដ្ឋាការចុះចតហើយទិដ្ឋាការនេះមិនបញ្ជាក់អំពីកំណត់មិនឱ្យពន្យាពេល(NO EXTENSION)ឬមិនអនុញ្ញាតិឱ្យផ្លាស់ប្តូរទិដ្ឋាការចុះចតទៅជាទិដ្ឋាការស្នាក់នៅទេនោះអ្នកស្នើសុំអាចស្នើសុំប័ណ្ណស្នាក់នៅសំរាប់អាណិកជនពីទីកន្លែងសេវាកម្មនាយកដ្ឋានអន្តោប្រវេសន្តនិងកិច្ចការចេញចូលប្រទេសក្រសួងមហាផ្ទៃផ្អែកតាមមូលហេតុសួរសុខទុក្ខពីញាតិសន្តានហើយមិនត្រូវការស្នើសុំប័ណ្ណទិដ្ឋាការស្នាក់នៅពីទីចាត់ការភាគខាងកណ្តាល យូនចាណាន ភាគ ខាងត្បូង ភាគខាងកើតនៃក្រសួងការបរទេស ។	១. សំណៅចំលងនៃបញ្ជីស្ថិតិគ្រួសារជនេសុសច្រើសតរេក្នុងស្រុក ដែលបានចេញឱ្យក្នុងរយៈកាល ៣ ខែ ទើបកន្លងទៅ ។(មានចុះបញ្ជីអាពាហ៍ពិពាហ៍ព្រមទាំងបញ្ជាក់ច្បាស់លាស់នូវសញ្ជាតិ ឈ្មោះ និងថ្ងៃ ខែ ឆ្នាំ កំណើតរបស់ប្តី ឬប្រពន្ធបរទេស) ។ ២. លិខិតមានចុះបញ្ជីអាពាហ៍ពិពាហ៍ដែលចេញហើយរដ្ឋាភិបាលប្រទេសនៃអ្នកស្នើសុំ(ប្រទេសដែលគ្មានប្រព័ន្ធចុះបញ្ជីអាពាហ៍ពិពាហ៍ ត្រូវតែផ្តល់សំបុត្រអាពាហ៍ពិពាហ៍) ។ ៣. លិខិតបញ្ជាក់និរទោសឬលិខិតបញ្ជាក់ជនសុចរិត ដែលចេញហើយរដ្ឋាភិបាលប្រទេសនៃអ្នកស្នើសុំ .(ក្នុងរយៈពេលមួយឆ្នាំចាប់ពីថ្ងៃពិនិត្យបញ្ជាក់ តែមិនលើសរយៈពេលមានប្រសិទ្ធិភាពដែលកំណត់ក្នុងលិខិតបញ្ជាក់) ៤. លិខិតបញ្ជាក់ពិនិត្យសុខភាពពេញលក្ខណៈ :ចេញឱ្យក្នុងរយពេល ៣ខែ ចេញផ្សាយដោយមន្ទីរពេទ្យពិនិត្យជនបរទេសដែលកំណាតដោយក្រសួងសុខាភិបាលនិងសង្គមកិច្ច ឬមន្ទីរពេទ្យមានសមត្ថភាពពេញលក្ខណៈ . ៥. លិខិតឆ្លងដែន (រវេលាមានសុខមាលភាព មិនតិចនឹង៦ខែ) ។ . ៦. រូបថតពណ៌ធម្មជាតិ២សន្លឹកដែលទំហំជា២តឹកក្នុង៦ខែ ។ ៧. ចូរយោងតាមវេបសាយនៃនាយកដ្ឋានកិច្ចការកុងស៊ុលនៃក្រសួងការបរទេស https://www.boca.gov.tw/cp-76-32-4a369-1.html (ចំពោះអ្នកកាន់លិខិតឆ្លងដែនសហរដ្ឋអាមេរិកត្រូវបង់សោហ៊ុយបំពេញបែបបទពាក្យ)។ (ឯកសារក្នុងប្រការ២-៣ជាឯកសារដែលតាក់តែងនៅបរទេស ត្រូវមានការពិនិត្យបញ្ជាក់និងទទួលស្គាល់ពីសំណាក់ស្ថានឯកអគ្គរដ្ឋទូតប្រចាំនៅបរទេស ព្រំទាំងមានឯកសារបកប្រែជាភាសាចិន ឬ ភាសាអង់គ្លេស) ។ (ប្តីប្រពន្ធបរទេសដែលការិវិហ្សាសំចត ប្រសិនបើហួសពីកាលបរិច្ឆេទ ពួកគេត្រូវតែចាកចេញពីតៃវ៉ាន់ ហើយមិនអាចស្នើសុំ ផ្លាស់វិហ្សាស្នាក់នៅក្នុងតៃវ៉ាន់ទេ) ។
ការស្នើសុំលិខិតស្នាក់នៅនៃ អណិកជនបរទេស	នាយកដ្ឋានអន្តោប្រវេសន្តនិងកិច្ចការចេញចូលប្រទេសក្រសួងមហាផ្ទៃ ទីកន្លែងសេវាកម្មនៅសាលាក្រុងគ្រប់ក្រុងផ្ទាល់និងខេត្ត （ក្រុង） នានា	១ ,អ្នកចូលដែនដោយកាន់ទិដ្ឋាការស្នាក់នៅ:（១）បំពេញសំណើសុំលិខិតស្នាក់នៅអណិកជនបរទេស១ច្បាប់ រូបថតពណ៌ធម្មជាតិ ពាក់កណ្តាលដងខ្លួន ថតពីខាងមុខក្នុង១ឆ្នាំ(ទំហំតាមកំណត់អត្តសញ្ញាណប័ណ្ណប្រជាពលរដ្ឋបច្ចុប្បន្ននេះ)(ដូចជាទំហំ នៃអត្តសញ្ញាណប័ណ្ណប្រជាពលរដ្ឋ សូមទៅទស្សនាវេបសាយពត៌មានពិភពលោកនៃមន្ទីរកិច្ចការអត្រានុកូលដ្ឋាននៃក្រសួងមហាផ្ទៃ https://www.ris.gov.tw/ ស្វែងរកពត៌មានអំពីទំហំ) ។（២）លិខិតឆ្លងដែននិងទិដ្ឋាការស្នាក់នៅ គឺត្រូវការច្បាប់ដើមនិងច្បាប់ចម្លងមួយច្បាប់រៀង១ខ្លួន(ច្បាប់ដើមនឹងសងវិញក្រោយការពិនិត្យមើល)（៣）ឯកសារបញ្ជាក់នូវមូលហេតុស្នើសុំលិខិតស្នាក់នៅ ។ ឧទាហរណ៍ សំណៅដើមនិងថតសៀវភៅគ្រួសាររបស់ប្តីឬប្រពន្ធតៃវ៉ាន់យើងដែលបានចុះបញ្ជីអាពាហ៍ពិពាហ៍ឬអត្តសញ្ញាណប័ណ្ណប្រជាពលរដ្ឋបានរៀបចំស្រេច (សំណៅដើមនឹងសងវិញក្រោយការពិនិត្យ)（៤）លិខិតបញ្ជាក់អំពីអាសយដ្ឋានស្នាក់នៅ ។（៥សោហ៊ុយប័ណ្ណស្នាក់នៅ១ឆ្នាំ១០០០យាន់តៃវ៉ាន់ថ្មី ២ឆ្នាំ២០០០យាន់តៃវ៉ាន់ថ្មី ៣ឆ្នាំ៣០០០យាន់តៃវ៉ាន់ថ្មី) ២. អ្នកដែលចង់ចូលប្រទេសចុះចតហួសរយៈពេល៦០ថ្ងៃដោយកាន់ទិដ្ឋាការចុះចតដែលមានប្រសិទ្ធិភាពហើយទិដ្ឋាការនេះមិនបញ្ជាក់អំពីកំណត់មិនឱ្យពន្យាពេលឬកំណត់ផ្សេងទៀតពីអង្គភាពទិដ្ឋាការ:（១）បំពេញសំណើសុំលិខិតស្នាក់នៅអណិកជនបរទេស១ច្បាប់ រូបថតពណ៌ធម្មជាតិ ពាក់កណ្តាលដងខ្លួនថតពីខាងមុខ ក្នុង១ឆ្នាំ ១ សន្លឹកទំហំតាមកំណត់អត្តសញ្ញាណប័ណ្ណប្រជាពលរដ្ឋបច្ចុប្បន្ននេះ)（២）លិខិតឆ្លងដែននិងទិដ្ឋាការស្នាក់នៅ គឺត្រូវការច្បាប់ដើមនិងច្បាប់ចម្លងមួយច្បាប់រៀង១ខ្លួន（៣）លិខិតបញ្ជាក់ការពិនិត្យមើលសុខភាពមានប្រសិទ្ធិភាពក្នុងរយៈពេល3ខែចាប់ពីថ្ងៃពិនិត្យមើល(អ្នកធ្វើត្រួតពិនិត្យសុខភាពនៅក្រៅប្រទេសហើយលិខិតបញ្ជាក់សុខភាពត្រូវពិនិត្យបញ្ជាក់ពីសំណាក់ស្ថានទូត)（៤）លិខិតបញ្ជាក់អំពីកំណត់ហេតុឧក្រិដ្ឋកម្មជាតិ នៃប្រទេសដើម ដែលចេញផ្សាយក្នុង១ឆ្នាំថ្មីៗនេះ (ត្រូវមានកំណត់ហេតុក្នុង៥ឆ្នាំថ្មីៗនេះប៉ុន្តែមិនអាចហួសពេលមានប្រសិទ្ធិភាពនៃលិខិតបញ្ជាក់នេះទេ ។ ត្រូវតែទទួលបញ្ជាក់ពីស្ថានទូតប្រចាំបរទេស ហើយត្រូវតែផ្តល់ភ្ជាប់នូវឯកសារបកប្រែជាភាសាចិន ដែលបានទទួលបញ្ជាក់ពីស្ថានទូតប្រចាំបរទេស ហើយទទួលបញ្ជាក់ពីសារការីក្នុងប្រទេស)（៥）លិខិតបញ្ជាក់ពាក់ព័ន្ធអំពីមូលហេតុស្នើសុំរឿងស្នាក់នៅ ដូចជាកចាត់ចែងសៀវភៅបញ្ជីអត្រានុកូលដ្ឋានសំរាប់ចុះបញ្ជីរៀបការឬអត្តសញ្ញាណប័ណ្ណរបស់ប្តីឬប្រពន្ធតៃវ៉ាន់យើង ត្រូវមានច្បាប់ដើមនិងច្បាប់ចម្លងមួយច្បាប់ (ច្បាប់ដើម ច្បាប់ដើមនឹងសងវិញក្រោយការពិនិត្យមើល)（៦）លិខិតបញ្ជាក់អំពីអាស័យដ្ឋានស្នាក់នៅ（៧）សោហ៊ុយប័ណ្ណស្នាក់នៅ: ១ឆ្នាំ១០០០យាន់តៃវ៉ាន់ថ្មី ៣ឆ្នាំ៣០០០យាន់តៃវ៉ាន់ថ្មីមួយទៀតត្រូវបង់ប្រាក់២២០០ប្រាក់តៃវ៉ាន់ថ្មីបន្ថែមសំរាប់បំពេញបែបបទប្រែទិដ្ឋាការចុះចតទៅជាប័ណ្ណស្នាក់នៅ ។ ※ ក្នុងអំឡុងពេលស្នាក់នៅ ក្នុងករណីបានផ្លាស់ប្តូរអាសយ័ដ្ឋានស្នាក់នៅ ត្រូវតែទៅស្នើសុំបំពេញបែបបទចុះបញ្ជីការផ្លាស់ប្តូរអាសយ័ដ្ឋានស្នាក់នៅ ក្នុង ១៥ ថ្ងៃ ក្រោយពីបានផ្លាស់ប្តូរអាសយ័ដ្ឋាននោះ ។ ※ កាលណាប្តីប្រពន្ធបរទេសទៅស្នើសុំធ្វើប័ណ្ណស្នាក់នៅសំរាប់ជនបរទេសលើកទី1 ឬប្រែប្រួលមូលហេតុស្នាក់នៅជាការផ្អែកញាតិសន្តានដោយសារៀបការ ត្រូវតែមានប្តីប្រពន្ធជនតៃវ៉ាន់ទៅជាមួយគ្នា ។ ※ បើសិនមុនពេលចុះចតនឹងចប់ហើយ អ្នកស្នើសុំនៅមិនទាន់ទទួលប័ណ្ណស្នាក់នៅសំរាប់ជនបរទេស ត្រូវតែចាកចេញពីព្រំដែនតាមកំណត់ ។
ការស្នើសុំលិខិតបញ្ជាក់ធ្វើបញ្ជាតួបនីយកម្មជាសញ្ជាតិចិនតៃវ៉ាន់ (ចាប់ពីថ្ងៃស្នើសុំទៅខាងមុខ ស្នាក់បំពេញច្បាប់បន្តហួស៣ឆ្នាំ ហើយ ស្នាក់ហួស១៨៣ថ្ងៃ រាល់ឆ្នាំដោយពិត)	ការិយាលិយកិច្ចការអត្រានុកូលដ្ឋាននៅតំបន់ស្នាក់នៅប្រគល់ឱ្យរដ្ឋាភិបាលទីក្រុងឱវាទ ខេត្ត(ក្រុង) រួចប្រគល់ក្រសួងមហាផ្ទៃ ដើម្បីចេញផ្សាយ	១. លិខិតស្នើសុំអនុញ្ញាតចូលសញ្ជាតិ(សូមប្តីប្រពន្ធបរទេសផ្ទាល់ខ្លួនមកដល់ការិយាល័យស្នើសុំ ហើយបោះពុម្ពលិខិតស្នើសុំតាមកុំព្យូទ័រ) ព្រមទាំងរូបថត១ សន្លឹក ថតពីខាងមុខ ពាក់កណ្តាលដងខ្លួន ពណ៌ធម្មជាតិ មិនពាក់មួក បានថតនៅក្នុង ២ ឆ្នាំទើបកន្លងទៅ (ដូចទំហំស្មើនៃរូបថតអត្តសញ្ញាណប័ណ្ណពលរដ្ឋ) ។ ២. លិខិតបញ្ជាក់ការតាំងលំនៅស្របច្បាប់របស់ជនបរទេស ឬលិខិតបញ្ជាក់ការ តាំងលំនៅជារៀងរហូតរបស់ជនបរទេស (ក្នុង30ថ្ងៃមុនពេលស្នាក់នៅនឹងចប់ហើយ សូមស្នើសុំពន្យារពេលស្នាក់នៅសិន) ។ ៣. លិខិតបញ្ជាក់មួយប្រភេទ តាម ប្រការទី៣អំពីគូរស្វាម៉ីជាសញ្ជាតិ ប្រទេសអាចនិយាយភាសាខ្មែរ និងអំណាចតំរូវរបស់ជនតៃវ៉ាន់ ។ (1)លិខិតបញ្ជាក់ថា ធ្លាប់រៀននៅសាលារដ្ឋឬឯកជនគ្រប់ថ្នាក់គ្រប់ប្រភេទអស់រយៈជាង1ឆ្នាំ ។ (2)លិខិតបញ្ជាក់ថា ធ្លាប់ចូលរួមវគ្គសិក្សាដែលបើកដោយអង្គការរដ្ឋាភិបាលតៃវ៉ាន់ ហើយម៉ោងសិក្សាសរុប ឬម៉ោងទាំងអស់លើសពី72ម៉ោង ។ (3)លិខិតបញ្ជាក់ថា ជាប់ប្រឡងភាសាមូលដ្ឋាននិងចំណេះដឹងអំពីសិទ្ធិនិងកាតព្វកិច្ចរបស់ពលរដ្ឋសំរាប់អ្នកដែលចង់ចូលសញ្ជាតិតៃវ៉ាន់ ត្រូវទទួលពិន្ទុលើសពី60 អ្នកមានអាយុជាង65ឆ្នាំ ត្រូវទទួលពិន្ទុលើសពី50 ។ ៤. សៀវភៅគ្រួសារដែលបានបំពេញបែបបទចុះបញ្ជីអាពាហ៍ពិពាហ៍រួចជាមួយប្តីឬប្រពន្ធតៃវ៉ាន់យើង(សំណៅដើមនឹងសងវិញក្រោយការពិនិត្យ) ប្តីឬប្រពន្ធជាជនតៃវ៉ាន់យើងមិនទាន់ចុះបញ្ជីគ្រួសារក្នុងស្រុក ហើយមិនទាន់បំពេញបែបបទចុះបញ្ជីអាពាហ៍ពិពាហ៍រួច ត្រូវតែផ្តល់ភ្ជាប់ឯកសារបញ្ជាក់អាពាហ៍ពិពាហ៍(ធ្វើនៅក្រៅប្រទេស ត្រូវតែទទួលបញ្ជាក់ពីស្ថានទូតប្រចាំបរទេស បើឯកសារជាភាសាបរទេស ត្រូវតែផ្តល់ភ្ជាប់នូវឯកសារបកប្រែជាភាសាចិន ដែលបានទទួលបញ្ជាក់ពីស្ថានទូតប្រចាំបរទេស ហើយទទួលបញ្ជាក់ពីសារការីក្នុងប្រទេស) ឯកសារបញ្ជាក់អត្តសញ្ញាណសញ្ជាតិ របស់ប្តីនិងប្រពន្ធបរទេសនិងតៃវ៉ាន់យើង អ្នកដែលរៀបការនៅក្នុងស្រុក ត្រូវភ្ជាប់មកនូវលិខិតបញ្ជាក់សភាពអាពាហ៍ពិពាហ៍ ដែលមានការពិនិត្យបញ្ជាក់និងទទួលស្គាល់ពីស្ថានឯកអគ្គរដ្ឋទូតឬស្ថានកុងស៊ុលប្រចាំនៅប្រទេសក្រៅនិងឯកសារបកប្រែជាភាសាចិន ។ ៥. សោហ៊ុយលិខិតបញ្ជាក់ ១២០០យាន់តៃវ៉ាន់ថ្មី ។ (សូមផ្ញើប្រាក់តាមប្រៃសណីយ៍ អ្នកទទួលប្រាក់ ក្រសួងមហាផ្ទៃ) ※ចំពោះប្រការទាំង៣ខាងលើនេះ បើលិខិតបញ្ជាក់បានចុះបញ្ជីក្នុងប្រព័ន្ធពត៌មានអត្រានុកូលដ្ឋាន ក៏មិនបាច់ប្រគល់ទេ ។ ※ឯកសារស្នាក់នៅ កំណត់ត្រាអំពីពេលវេលាចូលចេញពីព្រំដែន កំណត់ត្រាអំពីទោសឧក្រិដ្ឋកម្ម និងសំណៅសៀវភៅគ្រួសារដែលបានចុះបញ្ជីអាពាហ៍ពិពាហ៍ជាមួយប្តីឬប្រពន្ធជនតៃវ៉ាន់យើងរបស់អ្នកស្នើសុំត្រូវទទួលការត្រួតពិនិត្យពីអង្គការកិច្ចការ
ការស្នើសុំលិខិតស្នាក់នៅ នៅតំបន់តៃវ៉ាន់	នាយកដ្ឋានអន្តោប្រវេសន្តនិងកិច្ចការចេញចូលប្រទេសក្រសួងមហាផ្ទៃ ទីកន្លែងសេវាកម្មនៅសាលាក្រុងគ្រប់ក្រុងផ្ទាល់និងខេត្ត （ក្រុង） នានា ※ សូមភ្ជាប់ឯកសារទាំងអស់ពេលដាក់ពាក្យមកការិយាល័យកិច្ចការគ្រួសារសុំចូលសញ្ជាតិ	១. សំណើសុំតាំងលំនៅ១សន្លឹក ។ ព្រមទាំង រូបថតពណ៌ធម្មជាតិ ១ សន្លឹក មិនទាន់ពាក់មួក(ទំហំតាមកំណត់អត្តសញ្ញាណប័ណ្ណប្រជាពលរដ្ឋបច្ចុប្បន្ននេះ) ។ ២. សំណៅដើមនិងសំណៅចំលងនៃលិខិតអនុញ្ញាតឱ្យចូលសញ្ជាតិតៃវ៉ាន់ (សំណៅដើមនឹងសងវិញក្រោយការពិនិត្យ) ។ ៣. សំណៅដើមនិងសំណៅចំលងនៃប័ណ្ណស្នាក់នៅសំរាប់ជនបរទេស (សំណៅដើមនឹងសងវិញក្រោយការពិនិត្យ) ។ ៤. ឯកសារបញ្ជាក់អាស័យដ្ឋានស្នាក់នៅ ឧទាហរណ៍ សំណៅដើមនិងសំណៅចំលងនៃ សៀវភៅគ្រួសារដែលបានបំពេញបែបបទចុះបញ្ជីអាពាហ៍ពិពាហ៍រួចជាមួយប្តីឬប្រពន្ធតៃវ៉ាន់យើង ឬអត្តសញ្ញាណប័ណ្ណពលរដ្ឋ (សំណៅដើមនឹងសងវិញក្រោយការពិនិត្យ) ៥. សោហ៊ុយធ្វើលិខិតបញ្ជាក់ ១០០០យាន់តៃវ៉ាន់ថ្មី ។
ការស្នើសុំរំសាយសញ្ជាតិ	មន្ទីរគ្រប់គ្រងការចេញចូលដែននិងអន្តោប្រវេសន៍នៃនាយកដ្ឋានប៉ូលីសជាតិនៃក្រសួងមហាផ្ទៃ	※ អំពីកិច្ចការស្នើសុំលះបង់សញ្ជាតិប្រទេសដើម សូមពិគ្រោះ និងសួរយោបល់ជាមួយរដ្ឋាភិបាលប្រទេសដើម ឬស្ថានកុងស៊ុលប្រចាំតៃវ៉ាន់ ឬអង្គការតំណាង ប្រគល់សិទ្ធរបស់ប្រទេសនោះ ដែលប្រចាំនៅតៃវ៉ាន់ ។ ※ លិខិតបញ្ជាក់ការលះបង់សញ្ជាតិប្រទេសដើមដែលចេញផ្តល់ពីស្ថានទូតនិងកុងស៊ុលប្រចាំតៃវ៉ាន់ឬអង្គការតំណាងទទួលសិទ្ធិនៃបរទេស ត្រូវតែទទួលការត្រួតពិនិត្យម្តងទៀតពីក្រសួងការបរទេស លិខិតធ្វើនៅក្រៅប្រទេស ត្រូវតែទទួលការត្រួតពិនិត្យពីស្ថានទូតប្រចាំបរទេសនិងទទួលការត្រួតពិនិត្យម្តងទៀតក្រសួងការបរទេស ឯកសារបកប្រែជាភាសាចិនក៏ត្រូវទទួលការបញ្ជាក់ ហើយបញ្ជាក់ម្តងទៀតឬទទួលការបញ្ជាក់ពីត្រូវទទួលការបញ្ជាក់ពិសារការីនៅស្រុក ។ ※ចាប់ពីថ្ងៃអនុញ្ញាតចូលសញ្ជាតិ ត្រូវលើកឡើងលិខិតបញ្ជាក់ការរំសាយសញ្ជាតិប្រទេសដើមក្នុង1ឆ្នាំ ជូនឱ្យក្រសួងមហាផ្ទៃពិនិត្យនិងទម្កល់ទុក ។ បើសិនមិនអាចលើកឡើងលិខិតបញ្ជាក់ការរំសាយសញ្ជាតិប្រទេសដើមក្នុងពេលកំណត់ដូចខាងមុខ ត្រូវប្រគល់ឯកសារបញ្ជាក់ពាក់ព័ន្ធស្តីពីគេបានស្នើសុំប្រទេសដើមរំសាយសញ្ជាតិប្រទេសដើមក្នុង30ថ្ងៃមុនពេលកំណត់ដើម្បីស្នើសុំពន្យារពេល ។ ក្រោយពីក្រសួងការបរទេសបានពិនិត្យឃើញថា ជាការពិតដោយសារមូលហេតុច្បាប់ក្នុងប្រទេសដើមឬកិរិតនៃរបៀបរដ្ឋាបាល អាចយល់ព្រមពន្យារពេលបាន ។ ដល់ពេលពន្យារចប់ហើយ អ្នកនៅតែមិនអាចប្រគល់លិខិតបញ្ជាក់ការរំសាយសញ្ជាតិប្រទេសដើម ក្រសួងមហាផ្ទៃនឹងលុបចោលការអនុញ្ញាតចូលសញ្ជាតិរបស់គាត់ ។ ហើយមុនពេលលើកឡើងលិខិតបញ្ជាក់ការរំសាយសញ្ជាតិប្រទេសដើម មិនអនុញ្ញាតឱ្យតាំងលំនៅទេ ។
មិនទាន់ទទួលលិខិតបញ្ជាក់ការស្នើសុំរំសាយសញ្ជាតិប្រទេសដើម	ការិយាលិយកិច្ចការអត្រានុកូលដ្ឋាននៅតំបន់ស្នាក់នៅប្រគល់ឱ្យរដ្ឋាភិបាលទីក្រុងឱវាទ ខេត្ត(ក្រុង) រួចប្រគល់ក្រសួងមហាផ្ទៃ ដើម្បីពន្យារពេល	១. ពាក្យស្នើសុំពន្យារពេល ។ 2. ឯកសារបញ្ជាក់ពាក់ព័ន្ធស្តីពីគេបានស្នើសុំប្រទេសដើមរំសាយសញ្ជាតិប្រទេសដើម ។ ដូចជាច្បាប់ចម្លងនៃពាក្យស្នើសុំប្រទេសដើមរំសាយសញ្ជាតិប្រទេសដើមដែលបានសរសេរបំពេញ លិខិតបញ្ជាក់ថា រដ្ឋាភិបាលប្រទេសដើមបានទទួលពាក្យស្នើសុំឬបង្កាន់ដៃជាដើម លិខិតដែលចេញផ្តល់ពីស្ថានទូតនិងកុងស៊ុលប្រចាំតៃវ៉ាន់ឬអង្គការតំណាងទទួលសិទ្ធិនៃបរទេស ត្រូវតែទទួលការត្រួតពិនិត្យម្តងទៀតពីក្រសួងការបរទេស លិខិតធ្វើនៅក្រៅប្រទេស ត្រូវតែទទួលការត្រួតពិនិត្យពី ស្ថានទូតប្រចាំបរទេសនិងទទួលការត្រួតពិនិត្យម្តងទៀតក្រសួងការបរទេស ឯកសារបកប្រែជាភាសាចិនក៏ត្រូវទទួលការបញ្ជាក់ ហើយបញ្ជាក់ម្តងទៀតឬទទួលការបញ្ជាក់ពីត្រូវទទួលការបញ្ជាក់ពិសារការីនៅស្រុក ។ ※ បើសិនមិនដែលស្នើសុំពន្យារពេល ឬក្រសួងមហាផ្ទៃបដិសេធការស្នើសុំពន្យារពេល នឹងលុបចោលការអនុញ្ញាតចូលសញ្ជាតិ ។
ទទួលលិខិតបញ្ជាក់ការរំសាយសញ្ជាតិប្រទេសដើម	ការិយាលិយកិច្ចការអត្រានុកូលដ្ឋាននៅតំបន់ស្នាក់នៅប្រគល់ឱ្យរដ្ឋាភិបាលទីក្រុងឱវាទ ខេត្ត(ក្រុង) រួចប្រគល់ក្រសួងមហាផ្ទៃ ដើម្បីពិនិត្យនិងទម្កល់ទុក	១. ប័ណ្ណស្នាក់នៅតំបន់តៃវ៉ាន់ (ក្រោយពីពិនិត្យរួច នឹងប្រគល់វិញ) ។ ២. លិខិតបញ្ជាក់ការរំសាយសញ្ជាតប្រទេសដើម(លិខិតបញ្ជាក់ការលះបង់សញ្ជាតិប្រទេសដើមដែលចេញផ្តល់ពីស្ថានទូតនិងកុងស៊ុលប្រចាំតៃវ៉ាន់ឬអង្គការតំណាងទទួលសិទ្ធិនៃបរទេស ត្រូវតែទទួលការត្រួតពិនិត្យម្តងទៀតពីក្រសួងការបរទេស លិខិតធ្វើនៅក្រៅប្រទេស ត្រូវតែទទួលការត្រួតពិនិត្យពី ស្ថានទូតប្រចាំបរទេសនិងទទួលការត្រួតពិនិត្យម្តងទៀតក្រសួងការបរទេស ឯកសារបកប្រែជាភាសាចិនក៏ត្រូវទទួលការបញ្ជាក់ ហើយបញ្ជាក់ម្តងទៀតឬទទួលការបញ្ជាក់ពីត្រូវទទួលការបញ្ជាក់ពិសារការីនៅស្រុក) ។
ការស្នើសុំតាំងលំនៅ នៅតំបន់តៃវ៉ាន់ (ត្រូវតែក្រោយពីស្នើសុំលិខិតស្នាក់នៅនៅតំបន់តៃវ៉ាន់រួច ស្នាក់នៅពេញតាមពេលកំណត់ចាប់ពីថ្ងៃអនុញ្ញាតស្នាក់នៅទៅត្រូវបន្តស្នាក់នៅ ១ ឆ្នាំ ឬស្នាក់នៅពេញ ២ ឆ្នាំ ហើយស្នាក់នៅហួស ២៧០ ថ្ងៃរាល់ឆ្នាំ	នាយកដ្ឋានអន្តោប្រវេសន្តនិងកិច្ចការចេញចូលប្រទេសក្រសួងមហាផ្ទៃ ទីកន្លែងសេវាកម្មនៅសាលាក្រុងគ្រប់ក្រុងផ្ទាល់និងខេត្ត （ក្រុង） នានា	១. សំណើសុំតាំងលំនៅ១សន្លឹក ។ (ប្រមទាំង រូបថត ពាក់កណ្តាលដងខ្លួន ពណ៌ធម្មជាតិ ១ សន្លឹក មិនទាន់ពាក់មួក(ទំហំតាមកំណត់អត្តសញ្ញាណប័ណ្ណប្រជាពលរដ្ឋបច្ចុប្បន្ននេះ) ។ ២. លិខិតស្នាក់នៅនៅតំបន់តៃវ៉ាន់ ។ . ៣. សំណៅដើម និង ថតសៀវភៅគ្រួសារជនជាតិតៃវ៉ាន់នៃប្តីឬប្រពន្ធ និង អត្តសញ្ញាណប័ណ្ណប្រជាពលរ់តៃវ៉ាន់ ។ .(សំណៅដើមនឹងសងវិញក្រោយការពិនិត្យ អ្នកលះលែងគ្នាមិនចាំបាច់ទេ) ៤. ការបញ្ជាក់លើការពិនិត្យសុខភាពមានលក្ខណសមស្របក្នុង៣ខែ ។ .(ត្រូវពិនិត្យដោយ មន្ទីរពេទ្យដែលក្រសួងសុខាភិបាលនិងសង្គមកិច្ចយល់ព្រម ហើយសម្របតារាងទី២នៃតារាងប្រការត្រូវពិនិត្យដើម្បីការបញ្ជាក់លើការពិនិត្យសុខភាពដែលក្រុមរដ្ឋបាលកំណត់) ៥. ឯកសារបញ្ជាក់ដែលមានការពាក់ពន្ធទៀត ឧទាហរណ៍អ្នកស្នើសុំបានលែងលះជាមួយប្រជាជនតៃវ៉ាន់ ត្រូវផ្តល់សំណៅដើមនិងសំណៅចំលងនៃវិក្កយបត្រផ្ទះសម្បែងកំណត់ត្រាអាស័យដ្ឋានចុះបញ្ជីគ្រួសារត្រឹមត្រូវ ឬកិច្ចសន្យាជួល(សំណៅដើមនឹងសងវិញក្រោយការពិនិត្យ) ។ ៦. លិខិតអនុសិដ្ឋព្រមទាំងបំពេញឱ្យខានត្រឹមត្រូវនូវឈ្មោះអ្នកទទួលលិខិតនិងអាសយដ្ឋាន ។ . ៧. សោហ៊ុយធ្វើលិខិតបញ្ជាក់ ៦០០ យាន់តៃវ៉ាន់ថ្មី ។
ការស្នើសុំចុះបញ្ជីស្ថិតិគ្រួសារនិងទទួលអត្តសញ្ញាណបណ្ណពលរដ្ឋ	ការិយាលិយកិច្ចការអត្រានុកូលដ្ឋាន នៅតំបន់ចុះបញ្ជីគ្រួសារ	១. ច្បាប់ថតចំឡងនៃសេចក្តីជូនដំណឹងរបស់មន្ទីរគ្រប់គ្រងការចេញចូលដែននិងអន្តោប្រវេសន៍នៃនាយកដ្ឋានប៉ូលីសជាតិនៃក្រសួងមហាផ្ទៃប្រទល់ជូនទៅអ្នកស្នើសុំឱ្យបំពេញ សក្តិកម្មតាំងលំនៅ ។ . ២. សៀវភៅគ្រួសារ ។ អ្នកមានតែម្នាក់ក្នុងគ្រួសារ មិនចាំច់ភ្ជាប់មកទេ ។ ប៉ុន្តែត្រូវលើឯកសារបញ្ជាក់ រួមទាំងសក្តិកម្មកម្មសិទ្ធិនៃផ្ទះរបស់អ្នកមានតែម្នាក់ក្នុងគ្រួសារ) ។ ៣. រូបថតមុខ ពាក់កណ្តាលដងខ្លួនពណ៌ធម្មជាតិ មិនពាក់មួក ១ សន្លឹក បានថតនៅក្នុង២ឆ្នាំទើបកន្លងទៅ ទំហំនៃអត្តសញ្ញាណប័ណ្ណប្រជាពលរដ្ឋ សូមទៅទស្សនាវេបសាយពតិមានពិភពលោកនៃមន្ទីរកិច្ចការអត្រានុកូលដ្ឋាននៃក្រសួងមហាផ្ទៃ https://www.ris.gov.tw//app/portal/187 ស្វែងរកពតិមានអំពីទំហំ) ។ ៤. អ្នកទទួលបញ្ជីពលរដ្ឋលើកទីមួយត្រូវបង់ប្រាក់ ៣០ យាន់តៃវ៉ាន់ថ្មី អ្នកទទួលអត្តសញ្ញាណប័ណ្ណលើកទីមួយត្រូវបង់ប្រាក់ ៥០ យាន់តៃវ៉ាន់ថ្មី។ ※ ក្រោយពីការរាយការណ៍ការចុះបញ្ជីគ្រួសារ អ្នកស្នើសុំក៏អាចស្នើសុំទទួលអត្តសញ្ញាណប័ណ្ណតាមកំណត់ ពតិមានមានពាក់ព័ន្ធ សូមទៅការិយាលិយកិច្ចការអត្រានុកូលដ្ឋាននៅតំបន់ស្នាក់នៅបច្ចុប្បន្នចុះបញ្ជីគ្រួសារសួររកពតិមាន ។